មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៩-៩-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៩០៥/ ៤១៦ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **គីម ហាន់ស៊ីក** (KIM HAN SIK) ជនជាតិកូរ៉េ កើតនៅខេត្តណាមសាមៀន ប្រទេសកូរ៉េ ៥៨៩៨

០៧-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/ ៤១៧ ស្តីពីការតែងតាំងលោក **ឌិត គេង** ចៅក្រមតុលាការកំពូល ជាប្រធានតុលាការក្រុងភ្នំពេញ ៥៨៩៩

០៧-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤១៨ ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៩០០

០៧-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤១៩ ស្តីពីការដាក់វិន័យមន្ត្រីតុលាការចំនួន ០៧ រូប ៥៩០២

០៧-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤២០ស្តីពីការលុបឈ្មោះលោក **ត្រាំ ស៊ីថា** ព្រះរាជអាជ្ញារងកម្មសិក្សានៃអយ្យការអមតុលាការខេត្តក្រចេះ ចេញពីក្របខ័ណ្ឌចៅក្រម ៥៩០៤

១០-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤២១ ស្តីពី : ត្រូវបាននិរាករណ៍ ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៥/១៩៣ ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន និង ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០៥/២១១ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការ តែងតាំងសមាសភាពក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ៥៩០៥

II-រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៧-១០-២០០៥ -អនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងជីរដ្ឋ ៥៩០៦

២៩-៩-២០០៥ -អនុក្រឹត្យលេខ ៧៤៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥៩២៣

០៦-១០-២០០៥ -អនុក្រឹត្យលេខ ៧៥២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៩២៦

០៦-១០-២០០៥ -អនុក្រឹត្យលេខ ៧៥៣ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥៩២៧

០៦-១០-២០០៥ -អនុក្រឹត្យលេខ ៧៥៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥៩២៨

០៦-១០-២០០៥ -អនុក្រឹត្យលេខ ៧៥៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ៥៩២៩

០៧-១០-២០០៥ -អនុក្រឹត្យលេខ ៧៥៦ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥៩៣០

០៧-១០-២០០៥ -អនុក្រឹត្យលេខ ៧៥៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៩៣៣

០៧-១០-២០០៥ -អនុក្រឹត្យលេខ ៧៥៨ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៩៣៤
០៧-១០-២០០៥ -អនុក្រឹត្យលេខ ៧៥៩ អនក្រ.តត ស្តីពីការផ្លាស់ប្តូរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៩៣៥
០៧-១០-២០០៥ -អនុក្រឹត្យលេខ ៧៦០ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៩៣៦
០៧-១០-២០០៥ -អនុក្រឹត្យលេខ ៧៦១ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៩៣៧
០៧-១០-២០០៥ -អនុក្រឹត្យលេខ ៧៦២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥៩៣៨

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៣-៩-២០០៥ -ប្រកាសលេខ ៦០១ សហវ.ប្រក ស្តីពីការពន្យារពេលការអនុវត្តនីអាករលើការស្នាក់នៅ ៥៨៣៩

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៤-៩-២០០៥ -លិខិតលេខ ២១៣៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អេនីមល ឃឹង ស្តារ មេឌីខល អ៊ីដស & អិចដស ៥៩៤១
១៤-៩-២០០៥ -លិខិតលេខ ២១៣៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ហេង ហ៊ាប អ៊ិនវេសមេន ៥៩៤៣
១៤-៩-២០០៥ -លិខិតលេខ ២១៤៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស្ពែនខេម អ៊ិនធើណេសិនណល ខនស្រ្តាក់សិន ឃើក អិលធីឌី ៥៩៤៤
១៤-៩-២០០៥ -លិខិតលេខ ២១៤៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ផាន់ លក្ខិណា ខូ អិលធីឌី ៥៩៤៦
១៥-៩-២០០៥ -លិខិតលេខ ២១៤៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ខេមរាត្រាយ ៥៩៤៨
១៦-៩-២០០៥ -លិខិតលេខ ២១៥០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ណារ៉ាត្រា ឌីវេឡុបមេន ៥៩៥០
១៦-៩-២០០៥ -លិខិតលេខ ២១៥១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អង្គរ មាស គាព ៥៩៥២
១៦-៩-២០០៥ -លិខិតលេខ ២១៥២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ជេ អ ឌី អថូម៉ូធីវ គ្រេឌីង ៥៩៥៤
១៦-៩-២០០៥ -លិខិតលេខ ២១៥៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ជេ & អេច អេច ៥៩៥៦

១៦-៩-២០០៥ -លិខិតលេខ ២១៥៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ធី.ស៊ី.អ ៥៩៥៨

១៦-៩-២០០៥ -លិខិតលេខ ២១៦២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស៊ី.ធី.អ៊ី អាហរ៉ណា នីហរ៉ណា និង ដឹកជញ្ជូន ៥៩៦០

១៦-៩-២០០៥ -លិខិតលេខ ២១៦៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ឌី អឹម អេ (ខេមបូឌា) ៥៩៦២

១៦-៩-២០០៥ -លិខិតលេខ ២១៦៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
លីឌីង អ៊ិនធើណេសិនណាល ៥៩៦៣

១៦-៩-២០០៥ -លិខិតលេខ ២១៦៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ប៉ូរិក ហ្គាមេន (ខេមបូឌា) ៥៩៦៤

១៦-៩-២០០៥ -លិខិតលេខ ២១៦៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
តុង យុន ធីចថាយ (ខេមបូឌា) ៥៩៦៥

១៦-៩-២០០៥ -លិខិតលេខ ២១៦៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
នាគ សមុទ្រ ៥៩៦៦

១៩-៩-២០០៥ -លិខិតលេខ ២១៧០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស្រី សំណាង ៥៩៦៨

១៩-៩-២០០៥ -លិខិតលេខ ២១៧១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អិម ស៊ី អេច ខនសាល់ធីង ៥៩៧០

១៩-៩-២០០៥ -លិខិតលេខ ២១៧២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ខេមភាន អ៊ិនវេសមេន ៥៩៧២

១៩-៩-២០០៥ -លិខិតលេខ ២១៧៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ឥណ្ឌូឆាយណា អេកស្ពើត ៥៩៧៤

១៩-៩-២០០៥ -លិខិតលេខ ២១៧៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស៊ី ប៊ី ស៊ី ៥៩៧៦

១៩-៩-២០០៥ -លិខិតលេខ ២១៧៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស៊ី អិន ខេ ៥៩៧៨

នស/រកត/០៩០៥/៤១៦

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក គីម ហាន់ស៊ីក (KIM HAN SIK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៥៣ នៅខេត្តណាមសាមៀន ប្រទេសកូរ៉េ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣កប.០៥០៩.៤៣៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥

លេខ : ៣៩០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ.ថ្ងៃទី ០៧ ខែ ១០ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

៣/២

ព្រះរាជក្រឹត្យ

នស/រកត/១០០៥/៤១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស . រកត . ០៧០៤ . ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម
- បានទ្រង់យល់ ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំង លោក ជីវ កេង ចៅក្រមតុលាការកំពូល ជាប្រធានតុលាការក្រុងភ្នំពេញ ។

មាត្រា២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបាន សំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៥១០.៤៣៨

រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៥

លេខ : [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង៍ តាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៥/៤១៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស . រកត . ០៧០៤ . ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម
- បានទ្រង់យល់ ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានផ្ទេរការកិច្ច

១- លោក **ស៊ិន រិទ្ធ** ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តបាត់ដំបង អោយទៅបំរើការងារជាព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ។

២-លោក **ខេង ច្រីយ៉ា** ព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ អោយទៅបំរើការងារជាចៅក្រមសាលាឧទ្ធរណ៍ ។

៣-លោក **ឆឹក ចំន្ទសិបូរ** ព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ អោយទៅបំរើការងារជាចៅក្រមនៅសាលាឧទ្ធរណ៍ ។

៤-លោក **សេង ស៊ីវុត្ថា** ចៅក្រមនៅក្រសួងយុត្តិធម៌ អោយទៅបំរើការងារជាចៅក្រមសាលាឧទ្ធរណ៍ ។

៥-លោក **អ៊ុំ គឹមស្រ៊ី** ចៅក្រមនៅឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម អោយទៅបំរើការងារជាចៅក្រមតុលាការក្រុងភ្នំពេញ ។

៦-លោកស្រី **ចាន់ ម៉ារីណា** ចៅក្រមតុលាការខេត្តកណ្តាល អោយទៅបំរើការងារជាចៅក្រមតុលាការក្រុងភ្នំពេញ ។

៧-លោក **សុខ គល្យាណ** ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តព្រៃវែង អោយទៅបំរើការងារជាព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការក្រុងភ្នំពេញ ។

៨-លោកស្រី **គីម ដារី** ចៅក្រមតុលាការខេត្តបាត់ដំបង អោយទៅបំរើការងារជាចៅក្រមតុលាការខេត្តកណ្តាល ។

៩-លោក **សួស សំអាត** ចៅក្រមតុលាការខេត្តបាត់ដំបង អោយទៅបំរើការងារជាចៅក្រមតុលាការខេត្តបន្ទាយមានជ័យ ។

មាត្រា២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបាន សំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.១០០៥.៨៣៩

រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៥

លេខ ៨៧២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៥/៤១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស . រកត . ០៧០៤ . ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម
- បានទ្រង់យល់ ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានដាក់វិន័យ

១-លោក **នុប សុនុន** ចៅក្រម និងជាអនុប្រធានតុលាការក្រុងភ្នំពេញ ក្រោមរូបភាព ផ្លាស់ដោយបង្ខំចេញពីតុលាការក្រុងភ្នំពេញ ។

២-លោក **គីម សោភ័ណ** ចៅក្រមតុលាការក្រុងភ្នំពេញ ក្រោមរូបភាព ផ្លាស់ដោយបង្ខំចេញពីតុលាការក្រុងភ្នំពេញ ។

៣-លោកស្រី **ម៉ូនីញ ម៉ុណ្ណារី** ចៅក្រមតុលាការក្រុងភ្នំពេញ ក្រោមរូបភាព ផ្លាស់ដោយបង្ខំចេញពីតុលាការក្រុងភ្នំពេញ ។

៤-លោក តាន់ សេណារ៉ុង ចៅក្រមតុលាការក្រុងភ្នំពេញ ក្រោមរូបភាព ផ្លាស់ដោយបង្ខំចេញពីតុលាការក្រុងភ្នំពេញ ។

៥-លោកស្រី គង់ គួយ ចៅក្រម និងជាអនុប្រធានតុលាការខេត្តកណ្តាល ក្រោមរូបភាព ផ្លាស់ដោយបង្ខំចេញពីតុលាការខេត្តកណ្តាល ។

៦- លោក ឃន សុគុណ ចៅក្រមតុលាការខេត្តកណ្តាល ក្រោមរូបភាព ផ្លាស់ដោយបង្ខំចេញពីតុលាការខេត្តកណ្តាល ។

៧- លោក ឈី ឈន់ ព្រះរាជអាជ្ញារងនៃអយ្យការអមតុលាការខេត្តកណ្តាល ក្រោមរូបភាព ផ្លាស់ដោយបង្ខំចេញពីអយ្យការអមតុលាការខេត្តកណ្តាល ។

មាត្រា២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបាន សំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

នស/រកត.០៥១០.៨៤០

រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៥

លេខ ៧៩១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ១០ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

ព្រះរាជក្រឹត្យ

នស/រកត/១០០៥/៤២០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស . រកត . ០៧០៤ . ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩ នស.៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម
- បានទ្រង់យល់ ក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានលុបឈ្មោះលោក ថ្វាំ ស៊ីថា ព្រះរាជអាជ្ញារងកម្មសិក្សានៃអយ្យការអមតុលាការខេត្តក្រចេះ ចេញពីក្របខ័ណ្ឌចៅក្រម ។

មាត្រា២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបាន សំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៥.០៥១០.៤៤១

រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៥

លេខ ៣៦៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ ១០ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]

ព្រះរាជក្រឹត្យ

នស/រកត/១០០៥/៤២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុណជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៤០៥/១៩៣ ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើត ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០៥/២១១ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន
- បានទ្រង់យល់កិច្ចពិភាក្សារវាងគណបក្ស ហ៊្វុនស៊ិនប៉ិច គណបក្សប្រជាជនកម្ពុជា និងសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបាននិរាករណ៍ ព្រះរាជក្រឹត្យ លេខ នស/រកត/០៤០៥/១៩៣ ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន និងព្រះរាជក្រឹត្យ លេខ នស/រកត/០៥០៥/២១១ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ។

មាត្រា ២: រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៥១០.៤៤២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥

លេខ: ៣១៨៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ ១០ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការគ្រប់គ្រងដីរដ្ឋ

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/០៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្តក្រុង

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៥ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/០៥ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យ លេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីដែលមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធី ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៥

សម្រេច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១ .-

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ នីតិវិធី យន្តការ និងការរៀបចំផ្នែកស្ថាប័នសម្រាប់ការគ្រប់គ្រងដីរដ្ឋ លើ ÷

- ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ
- ការចុះបញ្ជី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ
- ការបង្កើត និងការថែរក្សាប្រព័ន្ធទិន្នន័យដីរដ្ឋ
- ការបែងចែក និងការគ្រប់គ្រងដីរដ្ឋ និង
- ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ ។

មាត្រា ២

ពាក្យបច្ចេកទេសទាំងឡាយខាងក្រោមនេះមានន័យដូចតទៅ ÷

- ដីរដ្ឋ " សំដៅដល់ ដីទាំងអស់ដែលជារបស់រដ្ឋ ហើយដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ឬស្ថាប័នថ្នាក់ជាតិ និងដីដែលត្រូវបានប្រគល់ឱ្យនីតិបុគ្គលសាធារណៈ ឬគ្រឹះស្ថានសាធារណៈដែលបានទទួលស្គាល់ដោយច្បាប់ថា ជានីតិបុគ្គលដើម្បីកាន់កាប់ ។
- អាជ្ញាធរដែនដី " សំដៅដល់ រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ។
- អាជ្ញាធរកាន់កាប់ដីរដ្ឋ " សំដៅដល់ ក្រសួង ឬ ស្ថាប័ន ឬ អាជ្ញាធរដែនដីដែលរដ្ឋបានប្រគល់ដីរដ្ឋណាមួយជាក់លាក់សម្រាប់គ្រប់គ្រង ថែរក្សាការពារ និងប្រើប្រាស់បំរើឱ្យស្ថាប័ន ។
- ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ " សំដៅដល់ក្រុមការងារធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ តាមស្រុក ខណ្ឌ ។

មាត្រា ៣ ..

គោលការណ៍ទូទៅសម្រាប់អនុវត្តក្នុងការគ្រប់គ្រងដីរដ្ឋមានដូចខាងក្រោម ÷

ក. ជាទូទៅ រដ្ឋគឺជាម្ចាស់នៃដីទាំងអស់ដែលមិនឋិតនៅក្រោមការកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាព ស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១ ។

ខ. ដីរដ្ឋរួមមាន ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ។

គ. ក្បាលដីរដ្ឋនីមួយៗត្រូវចុះបញ្ជី ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ នៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

ឃ. ដីរដ្ឋអាចផ្តល់ឱ្យជាសម្បទានដីសង្គមកិច្ច ជាសម្បទានដីសេដ្ឋកិច្ច ឬជាសម្បទានផ្សេងៗទៀតបានលុះត្រាតែដីនោះត្រូវបានចុះបញ្ជីថា ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ និងត្រូវអនុវត្តតាមនីតិវិធីច្បាប់ ។

មាត្រា ៤ ..

ដីសាធារណៈរបស់រដ្ឋជាដីដែលមានជាប់ផលប្រយោជន៍សាធារណៈ និងឋិតនៅក្នុងប្រភេទជាក់លាក់នៃទ្រព្យដែលមានផលប្រយោជន៍សាធារណៈដូចខាងក្រោម ÷

ក. ទ្រព្យទាំងឡាយដែលបង្ហាញការកើតឡើងពីធម្មជាតិ ដូចជា ÷

១. ព្រៃឈើ ។

២. ផ្លូវទឹកដែលនាវា ឬក្បូនអាចចេញចូលបាន បណ្តែតបាន ។

៣. បឹងធម្មជាតិ ។

៤. ច្រាំងទន្លេដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន ។

៥. ត្រើយសមុទ្រ ។

ខ. ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍សាធារណៈទូទៅ ដូចជា ÷

១. តំរបាន ។

២. កំពង់ផែ ។

៣. ផ្លូវដែក ។

៤. ស្ថានីយរថភ្លើង ។

៥. ព្រលានយន្តហោះ ។

គ. ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ តាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំ ដូចជា ÷

១. ផ្លូវថ្នល់ ។

២. ផ្លូវលំ ។

៣. ផ្លូវរទេះ ។

៤. ផ្លូវដើរ ។

៥. សួនច្បារ ឧទ្យានសាធារណៈ ។

៦. ដីចំណី ។

ឃ. ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈ ដូចជា ÷

១. សាលារៀន ឬ អគារសិក្សាសាធារណៈ ។

២. អគាររដ្ឋបាល ។

៣. មន្ទីរពេទ្យសាធារណៈ ។

ង. ដែនបម្រុងធម្មជាតិការពារដោយច្បាប់ ។

ច. បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ ។

ឆ. អចលនវត្ថុជាព្រះរាជទ្រព្យ ដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស ។

ជ. ដីផ្សេងៗទៀតដែលមានចរិតបំរើផលប្រយោជន៍សាធារណៈ និងដីដែលមានមូលដ្ឋានគតិយុត្តកំណត់រួចហើយ ។

មាត្រា ៥ .-

ដីឯកជនរបស់រដ្ឋ រួមមាន ដីទាំងអស់ដែលមិនមែនជាដីសាធារណៈរបស់រដ្ឋ និងមិនមែនជាដីដែលកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាព ស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១។ ដីឯកជនរបស់រដ្ឋ មានរួមបញ្ចូលដូចជា ទ្រព្យនិទាឃាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឱ្យរដ្ឋដោយស្ម័គ្រចិត្ត ឬទ្រព្យដែលមិនអាចកំណត់បាននូវអត្តសញ្ញាណកោតិ ឬកម្មសិទ្ធិករស្របច្បាប់ ។

ជំពូកទី ២
ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ

មាត្រា ៦ ._

ក. ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ជាដំណើរការមួយដែលមានលក្ខណៈសម្របសម្រួល និងមានតម្លាភាព ធ្វើឡើងដោយក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ក្រោមការដឹកនាំរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ដើម្បីប្រមូល និងចងក្រងឯកសារដូចខាងក្រោម ÷

១. ទីតាំង និងព្រំប្រទល់ប្រហាក់ប្រហែលនៃដីរដ្ឋ ។

២. ព័ត៌មាននានាដែលមានប្រយោជន៍សម្រាប់ការចុះបញ្ជីដីរដ្ឋថា ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ។

៣. ព័ត៌មានអំពីប្រភេទដី និងការប្រើប្រាស់បច្ចុប្បន្ន ប្រសិនបើមាន ។

ខ. ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ត្រូវធ្វើឡើងដោយកិច្ចសហការរួមគ្នាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ហើយត្រូវបង្ហាញរាល់ការអះអាងទាំងអស់របស់ក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីនោះទាក់ទងនឹងឋានៈនៃដី និងអាណត្តិកាន់កាប់ ។

គ. តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចផ្តល់ព័ត៌មាន និងឯកសារទាក់ទងនឹងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋទាំងអស់ដែលឋិតនៅក្រោមអាណត្តិកាន់កាប់របស់ក្រសួងស្ថាប័ននោះ ។ អាជ្ញាធរដែនដីមានភារកិច្ចផ្តល់ព័ត៌មានទាក់ទងនឹងដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋទាំងអស់ដែលឋិតនៅក្នុងដែនដីរបស់ខ្លួន ទោះបីដីនោះឋិត ឬមិនឋិតនៅក្រោមអាណត្តិកាន់កាប់របស់ខ្លួនក៏ដោយ ។

ឃ. តំណាងរបស់ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីណាមួយដែលអះអាង អំពីអាណត្តិកាន់កាប់លើក្បាលដីណាមួយជាកម្មសិទ្ធិរបស់រដ្ឋ ឬអះអាងថា ជាដីសាធារណៈរបស់រដ្ឋ ត្រូវផ្តល់ព័ត៌មាន និងឯកសារគាំទ្រ ។

ង. រាល់ព័ត៌មានដែលប្រមូលបានពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ត្រូវចាត់ទុកជាព័ត៌មានបឋម និងមិនទាន់មានការបញ្ជាក់ច្បាស់លាស់ជាផ្លូវការ រហូតដល់ដីនោះត្រូវបានចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដី ។

មាត្រា ៧ ._

ក. ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌត្រូវបំពេញកិច្ចការនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋដោយមានជំនួយបច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ខ. ក្រុមការងារដីរដ្ឋថ្នាក់ស្រុកខណ្ឌត្រូវប្រមូលព័ត៌មានទាក់ទងនឹងដីរដ្ឋនៅក្នុងឃុំ សង្កាត់ ពីសមាជិកក្រុមការងាររបស់ខ្លួន និងពីតំណាងរបស់រាល់ស្ថាប័នរដ្ឋ និងអាជ្ញាធរដែនដីនៃឃុំ សង្កាត់នីមួយៗក្នុងស្រុក ខណ្ឌ ។

គ. ក្រុមការងារជីវវដ្តថ្នាក់ស្រុកខណ្ឌត្រូវរៀបចំរបាយការណ៍ការងារ ដែលមានបញ្ចូលព័ត៌មានដូចបានរៀបរាប់ក្នុងមាត្រា ៦ ក ផែនទីបង្ហាញពីការអះអាងរបស់តំណាងក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីទាំងអស់ ព្រមទាំងសេចក្តីសង្ខេបអំពីមតិសាធារណៈ។

ឃ. ក្រុមការងារជីវវដ្តថ្នាក់ស្រុក ខណ្ឌត្រូវរកការឯកភាពគ្នាក្នុងចំណោមក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីទាំងអស់ដែលមានការពាក់ព័ន្ធ។ ប៉ុន្តែ ប្រសិនបើមិនអាចសម្រេចបាននូវការឯកភាពមតិគ្នាទេ នោះក្រុមការងារជីវវដ្តថ្នាក់ស្រុក ខណ្ឌត្រូវបញ្ជាក់អំពីការអះអាងដែលមិនស្របគ្នាទាំងឡាយនៅក្នុងរបាយការណ៍ ដែលត្រូវដាក់ជូនទៅគណៈកម្មាធិការគ្រប់គ្រងជីវវដ្តថ្នាក់ខេត្ត ក្រុង។

ង. មុននឹងដាក់របាយការណ៍ការងារជូនគណៈកម្មាធិការគ្រប់គ្រងជីវវដ្តថ្នាក់ខេត្ត ក្រុង ក្រុមការងារជីវវដ្តថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើការបិទផ្សាយជាសាធារណៈរយៈពេល ៣០ (សាមសិប) ថ្ងៃ នូវសេចក្តីសង្ខេបអំពីការអះអាងអំពីផែនទីបង្ហាញពីការអះអាង និងសេចក្តីពន្យល់ច្បាស់លាស់អំពីគោលបំណងនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីជីវវដ្ត សម្រាប់ឱ្យសាធារណជនចូលរួមផ្តល់មតិយោបល់ និងត្រូវផ្តល់ជូនតាមការស្នើសុំ នូវសំណៅថតចម្លងនៃឯកសារដែលបានបិទផ្សាយ ដោយតម្រូវឱ្យបង់ថ្លៃសមស្រប។

ច. ក្រុមការងារជីវវដ្តថ្នាក់ស្រុកខណ្ឌ ត្រូវធ្វើការសង្ខេបមតិយោបល់សាធារណៈដែលទទួលបាន ហើយបញ្ចូលសេចក្តីសង្ខេបនោះ ទៅក្នុងរបាយការណ៍ការងាររបស់ខ្លួន ដើម្បីដាក់ជូនទៅគណៈកម្មាធិការគ្រប់គ្រងជីវវដ្តថ្នាក់ខេត្ត ក្រុង។

ឆ. ប្រសិនបើមានការអះអាងមិនស្របគ្នា គណៈកម្មាធិការគ្រប់គ្រងជីវវដ្តថ្នាក់ខេត្ត ក្រុង ត្រូវធ្វើការស៊ើបអង្កេតការអះអាងរបស់ស្ថាប័ន ឬអាជ្ញាធរដែនដី តាមការបង្ហាញនៅក្នុងរបាយការណ៍របស់ក្រុមការងារជីវវដ្តថ្នាក់ស្រុក ខណ្ឌ និងត្រូវពិចារណារាល់មតិយោបល់សាធារណៈដែលបានសង្ខេបបញ្ចូលនៅក្នុងរបាយការណ៍នោះ។

ជ. ប្រសិនបើគ្មានការអះអាងដែលមិនស្របគ្នា ឬប្រសិនបើគណៈកម្មាធិការគ្រប់គ្រងជីវវដ្តថ្នាក់ខេត្ត ក្រុង អាចសម្រេចបានការឯកភាពមតិគ្នាលើការអះអាងដែលមិនស្របគ្នានោះ លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីជីវវដ្ត ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ និងផែនទីជីវវដ្តដែលត្រូវបង្កើតឡើងស្របតាមអនុក្រឹត្យនេះ។

ឈ. ប្រសិនបើគណៈកម្មាធិការគ្រប់គ្រងជីវវដ្តថ្នាក់ខេត្ត ក្រុងមិនអាចសម្រេចបានការឯកភាពមតិគ្នាលើការអះអាងដែលមិនស្របគ្នា លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីជីវវដ្ត រួមទាំងព័ត៌មានអំពីការអះអាងដែលមិនស្របគ្នានោះ ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ និងផែនទីជីវវដ្ត។

៣. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញប្រកាសណែនាំលំអិត ស្តីពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីជីវវដ្ត និងអំពីក្រុមការងារជីវវដ្តថ្នាក់ស្រុក ខណ្ឌ។ ប្រកាសណែនាំនេះត្រូវមានបញ្ចូលលក្ខខណ្ឌលំអិតសម្រាប់ឱ្យសាធារណជនទូទៅ និងអាជ្ញាធរប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចបានដឹងឮ អំពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីជីវវដ្តក្នុងមូលដ្ឋានរបស់ខ្លួន និងផ្តល់ឱកាសគ្រប់គ្រាន់ដល់សាធារណជន និងសហគមន៍ជនជាតិដើមភាគតិចបានចូលរួមផ្តល់មតិយោបល់ លើរបាយការណ៍របស់ក្រុមការងារជីវវដ្តថ្នាក់ស្រុក ខណ្ឌ។

ជំពូកទី ៣
ការចុះបញ្ជីដីរដ្ឋ

មាត្រា ៨ .-

ក. ការចុះបញ្ជីដីរដ្ឋត្រូវធ្វើឡើងផ្អែកលើការចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ អនុលោមតាមអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬផ្អែកលើការចុះបញ្ជីដែលមានលក្ខណៈដាច់ដោយដុំ អនុលោមតាមអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីដាច់ដោយដុំ។

ខ. ដំណើរការចុះបញ្ជីដីរដ្ឋ រួមមាន ÷

១. ការបញ្ជាក់កម្មសិទ្ធិរបស់រដ្ឋលើដី។

២. ការកំណត់ព្រំប្រទល់ច្បាស់លាស់លើដី។

៣. ការដោះស្រាយទំនាស់ដោយអាជ្ញាធរមានសមត្ថកិច្ច។

៤. ការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី។

គ. ប្រសិនបើមានការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋមុនពេលធ្វើការចុះបញ្ជីដី លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋនោះ មិនមែនជាព័ត៌មានសម្រេចឡើយ តែជាព័ត៌មានបឋមសម្រាប់ប្រើប្រាស់ ក្នុងដំណើរការចុះបញ្ជីដីរដ្ឋ ។

ឃ. ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដី ដែលអះអាងថា ក្បាលដីរដ្ឋណាមួយជាដីសាធារណៈរបស់រដ្ឋ ត្រូវផ្តល់ឯកសារ និងភស្តុតាងផ្សេងៗទៀតដែលបង្ហាញថា ដីនោះត្រូវបានរាប់បញ្ចូលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ដូចមានចែងក្នុងមាត្រា ១៥ នៃច្បាប់ភូមិបាលឆ្នាំ ២០០១។

ង. ក្នុងការចុះបញ្ជីដីលើកដំបូង ដីរដ្ឋដែលមិនបានបង្ហាញឱ្យឃើញថា មានចរិតបំរើប្រយោជន៍សាធារណៈ ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ និងមាត្រា ១៥ នៃច្បាប់ភូមិបាល ត្រូវចុះបញ្ជីជាដីឯកជនរបស់រដ្ឋ។

មាត្រា ៩ .-

ក. នៅក្នុងការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធលើកដំបូង ដីរដ្ឋនៅក្នុងតំបន់វិនិច្ឆ័យត្រូវបានកំណត់ព្រំប្រទល់ ហើយដីនោះត្រូវបានចុះក្នុងសៀវភៅគោលបញ្ជីដីធ្លីថា ជាដីរដ្ឋ។

ខ. ឋានៈជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋត្រូវបានចុះបញ្ជី ប្រសិនបើ

- ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋត្រូវបានធ្វើចប់មុនការចុះបញ្ជី ដោយគ្មានការអះអាងណាមួយរបស់ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលមិនស្របគ្នា ឬ
- ទោះបីមិនទាន់មានការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋក្តី ប៉ុន្តែមានព័ត៌មានដែលអាចឱ្យធ្វើការសន្និដ្ឋានបាន អំពីឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីនោះ ហើយក្រសួង-ស្ថាប័ន និងអាជ្ញាធរដែនដីទាំងឡាយក៏មានការឯកភាពមតិគ្នាលើឋានៈនៃដីនោះថា ជាដីសាធារណៈរបស់

រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ។

មាត្រា ១០ ..

ក. ក្នុងការចុះបញ្ជីដីធ្លីដែលមានលក្ខណៈដាច់ដោយដុំលើកដំបូង ដីរដ្ឋដែលមានព្រំប្រទល់ជាក់លាក់ត្រូវបានចុះបញ្ជីដោយមានឋានៈច្បាស់លាស់ ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ។

ខ. ត្រូវអនុវត្តនីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដីរដ្ឋដែលមានចែងក្នុងជំពូកទី ៤ នៃអនុក្រឹត្យនេះ មុននឹងធ្វើការចុះបញ្ជីដីបាន ចំពោះស្ថានភាពដូចខាងក្រោម ÷

- ការធ្វើអត្តសញ្ញាណកម្ម និងផែនទីដីរដ្ឋត្រូវបានធ្វើរួច ហើយមានការអះអាងមិនស្របគ្នាពីក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដី ឬ
- ដីដែលគ្មានព័ត៌មានច្បាស់លាស់អំពីឋានៈ និង អំពីការប្រើប្រាស់បច្ចុប្បន្ននៃដីនោះ ។

ជំពូកទី ៤

ការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ

មាត្រា ១១ ..

នីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដីរដ្ឋដែលចែងក្នុងជំពូកនេះ ត្រូវយកមកអនុវត្តលើករណី ដូចខាងក្រោម ÷

១. ដីនោះត្រូវបានចុះបញ្ជីថា ជាដីរដ្ឋនៅក្នុងការអនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ប៉ុន្តែដីនោះមិនទាន់ត្រូវបានធ្វើចំណាត់ថ្នាក់ ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋនៅឡើយ ។

២. ការចុះបញ្ជីដីរដ្ឋមានលក្ខណៈដាច់ដោយដុំលើកដំបូង ចំពោះដីដែលមិនទាន់អាចចុះបញ្ជីបាន ដោយសារហេតុផលដែលរៀបរាប់ក្នុងមាត្រា ១០ ខ ខាងលើ ។

មាត្រា ១២ ..

ក. ក្នុងករណីដែលតម្រូវឱ្យអនុវត្តនីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដី អនុលោមតាមជំពូកនេះ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានភារកិច្ចផ្ដល់អនុសាសន៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីឋានៈនៃដីនោះ ដោយបញ្ជាក់ថា ការធ្វើចំណាត់ថ្នាក់ដីនោះ អនុលោមតាមច្បាប់ភូមិបាល និងច្បាប់ផ្សេងៗទៀត ។

ខ. ប្រសិនបើបានធ្វើអត្តសញ្ញាណកម្ម និងផែនទីដីរដ្ឋរួចហើយ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវពិចារណារបាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ដែលមានរួមបញ្ចូលទាំងមតិយោបល់សាធារណៈ មុនពេលធ្វើការផ្ដល់អនុសាសន៍ ។

គ. ប្រសិនបើមិនទាន់បានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋទេ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវធ្វើការស៊ើបអង្កេតរាល់ការអះអាងដែលមិនស្របគ្នារបស់ស្ថាប័ន ឬអាជ្ញាធរដែនដី និងផ្ដល់ឱកាសឱ្យសាធារណជនចូលរួមមតិលើការធ្វើចំណាត់ថ្នាក់នោះ ។

ឃ. ប្រសិនបើគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង អាចសម្រេចបានការឯកភាពមតិគ្នាលើការធ្វើចំណាត់ថ្នាក់ដីនោះ ថាជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ អនុលោមតាមច្បាប់ភូមិបាល និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវលើកអនុសាសន៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីឋានៈនៃដីនោះ ។

ង. ប្រសិនបើក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ យល់ព្រមតាមអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ក្រសួងត្រូវចុះបញ្ជីចំណាត់ថ្នាក់នៃដីនោះនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ស្របតាមអនុសាសន៍ ។ ប៉ុន្តែ ប្រសិនបើក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនយល់ព្រមតាមអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋដីថ្នាក់ខេត្ត ក្រុងទេ ក្រសួងត្រូវបញ្ជូនករណីនោះទៅក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

ច. ប្រសិនបើគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុងមិនអាចសម្រេចបានការឯកភាពមតិគ្នា អំពីឋានៈនៃដីនោះទេ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីដើម្បីពិចារណាបន្តទៀត ។

ឆ. ប្រសិនបើក្រុមប្រឹក្សាគោលនយោបាយដីធ្លីអាចសម្រេចបានការឯកភាពមតិគ្នាអំពីឋានៈនៃដីនោះថា ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ផ្អែកលើមូលដ្ឋានច្បាប់ភូមិបាល និងច្បាប់ផ្សេងៗទៀតដែលពាក់ព័ន្ធ ក្រុមប្រឹក្សាគោលនយោបាយដីធ្លីត្រូវផ្តល់អនុសាសន៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីការចុះបញ្ជីដីនោះ ។

ជ. ប្រសិនបើក្រុមប្រឹក្សាគោលនយោបាយដីធ្លី មិនអាចសម្រេចបានការឯកភាពមតិគ្នាអំពីឋានៈនៃដីនោះទេ ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបញ្ជូនករណីនោះទៅគណៈរដ្ឋមន្ត្រីដើម្បីសម្រេចលើការធ្វើចំណាត់ថ្នាក់ដីនោះ ។

ឈ. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចុះបញ្ជីចំណាត់ថ្នាក់ដីរដ្ឋនោះនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ស្របតាមសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី ។

ញ. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញប្រកាសណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ។

ជំពូកទី ៥
ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ

មាត្រា ១៣ .-

ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ គឺជាការប្តូរឋានៈដីរដ្ឋដែលត្រូវបានចុះបញ្ជីថា ជាដីសាធារណៈរបស់រដ្ឋ ឬ ជាដីឯកជនរបស់រដ្ឋរួចហើយ ÷

- ពីដីឯកជនរបស់រដ្ឋទៅជាដីសាធារណៈរបស់រដ្ឋ ឬ
- ពីដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ ។

មាត្រា ១៤ ._

ក. លើកលែងតែមានច្បាប់ចែងផ្សេងពីនេះ ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុងជំពូកនេះ ។

ខ. ការធ្វើចំណាត់ថ្នាក់ឡើងវិញ ពីដីឯកជនរបស់រដ្ឋទៅជាដីសាធារណៈរបស់រដ្ឋ ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

គ. ការធ្វើចំណាត់ថ្នាក់ឡើងវិញពីដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ ត្រូវធ្វើឡើងដោយអនុលោមតាមមាត្រា១៦ នៃច្បាប់ភូមិបាលឆ្នាំ២០០១។

មាត្រា ១៥ ._

ក. ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីក្នុងមូលដ្ឋានណាមួយអាចផ្តួចផ្តើមការធ្វើចំណាត់ថ្នាក់ដីរដ្ឋមួយឡើងវិញ ដោយដាក់សំណើជាលាយល័ក្ខណ៍អក្សរជូនទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុងដែលពាក់ព័ន្ធ។ សំណើនោះត្រូវពណ៌នាអំពីដីដែលស្នើសុំឱ្យធ្វើចំណាត់ឡើងវិញ ដោយមានបង្ហាញលេខសម្គាល់ក្បាលដីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ហើយត្រូវបញ្ជាក់មូលហេតុជាក់លាក់សម្រាប់ការស្នើឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញ។

ខ. ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីបានទទួលសំណើ ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវចាត់តាំងក្រុមត្រួតពិនិត្យមួយដែលមានតំណាងរបស់មន្ទីរដែលមានជំនាញបច្ចេកទេសពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យសំណើ និងលើកអនុសាសន៍អំពីសំណើនោះ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង។

គ. ក្រុមត្រួតពិនិត្យនោះត្រូវបញ្ចប់ការត្រួតពិនិត្យក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ បន្ទាប់ពីត្រូវបានចាត់តាំងឡើង។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុងអាចអនុញ្ញាតឱ្យពន្យារពេលមួយដង ឬច្រើនដង ប៉ុន្តែទោះក្នុងករណីណាក៏ដោយក្រុមត្រួតពិនិត្យត្រូវតែបញ្ចប់ការត្រួតពិនិត្យ ព្រមទាំងរបាយការណ៍ស្តីពីការត្រួតពិនិត្យនោះ ក្នុងរយៈពេលមិនលើសពី ៩០ (កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃចាត់តាំង។

ឃ. ក្រុមត្រួតពិនិត្យដែលត្រូវបានចាត់តាំង ត្រូវបិទផ្សាយជាសាធារណៈសម្រាប់រយៈពេល ៣០ (សាមសិប) ថ្ងៃ អំពីការស្នើសុំឱ្យមានការធ្វើចំណាត់ថ្នាក់ឡើងវិញ ។ ក្នុងពេលនោះ ក្រសួង ស្ថាប័ននានា អាជ្ញាធរដែនដី និងអ្នកលើកសំណើ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន ឬសង្គមស៊ីវិល និងប្រជាពលរដ្ឋនៃ ឃុំ សង្កាត់ដែលពាក់ព័ន្ធ អាចផ្តល់មតិយោបល់របស់ខ្លួន ចំពោះសំណើនោះដល់ក្រុមត្រួតពិនិត្យ ប្រសិនបើមាន។

ង. ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីក្រុមត្រួតពិនិត្យបានដាក់ជូនរបាយការណ៍ត្រួតពិនិត្យ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវលើកអនុសាសន៍របស់ខ្លួនជាលាយល័ក្ខណ៍អក្សរជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីថា គួរទទួលយក ឬបដិសេធ ឬតម្រូវឱ្យធ្វើការកែសម្រួលលើសំណើនោះ។

ច. ក្រុមប្រឹក្សាគោលនយោបាយដីធ្លីត្រូវពិនិត្យអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ហើយលើកអនុសាសន៍ជូនគណៈរដ្ឋមន្ត្រី។

ឆ. ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីក្នុងមូលដ្ឋានដែលលើកសំណើនោះត្រូវរៀបចំឯកសារ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីនូវសេចក្តីព្រាងអនុក្រឹត្យ ឬច្បាប់ស្តីពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋជាក់លាក់ឡើងវិញ តាមករណីជាក់ស្តែង

ដោយមានភ្ជាប់ជាមួយនូវអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង និងរួមទាំងអនុសាសន៍របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លីផង ។

ជ. នៅពេលដែលអនុក្រឹត្យ ស្តីពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញត្រូវបានសម្រេច ឬច្បាប់ស្តីពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញត្រូវបានប្រកាសឱ្យប្រើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបញ្ចូលព័ត៌មាននៃការធ្វើចំណាត់ថ្នាក់ឡើងវិញ ទៅក្នុងប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ និងត្រូវចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

ជំពូកទី ៦
ប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ

មាត្រា ១៦ ._

ប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ ជាទិន្នន័យដែលមានផ្ទុកព័ត៌មាន អំពីដីរដ្ឋដូចខាងក្រោម ÷

១-ព័ត៌មានបឋមមិនទាន់បានបញ្ជាក់ច្បាស់លាស់ ដែលបានមកពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ។

២-ព័ត៌មាន ដែលបង្ហាញថា ដីនោះបានចុះបញ្ជីរួចហើយ ឬមិនទាន់បានចុះបញ្ជី ។

៣-អត្តសញ្ញាណនៃក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដី ដែលមានអាណត្តិកាន់កាប់ដីនោះ ។

៤-ឯកសារផ្តល់ដោយក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលមានអាណត្តិកាន់កាប់ដីនោះ ដែលបង្ហាញអំពីការអះអាងពីឋានៈនៃដីនោះ ។

៥-ព័ត៌មានអំពីប្រទានកម្ម សម្បទាន ការជួល ឬបន្ទុកផ្សេងៗទៀតលើដីនោះ ។

មាត្រា ១៧ ._

ក. គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានភារកិច្ចថែរក្សា និងធ្វើចរន្តការប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋប្រចាំខេត្តក្រុង ។

ខ. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវកំណត់លក្ខណៈបច្ចេកទេសនៃប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ និងត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការថែរក្សា និងការធ្វើចរន្តការប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ ។

គ. ប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋនេះ បំពេញទិន្នន័យឱ្យបញ្ជីទ្រព្យសម្បត្តិរដ្ឋ ដែលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបំពេញឱ្យសៀវភៅគោលបញ្ជីដីធ្លី ដែលគ្រប់គ្រងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ឃ. សាធារណជនមានសិទ្ធិមើលប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋក្នុងថ្ងៃធ្វើការ និងទទួលបានឯកសារថតចម្លង ដោយត្រូវបង់ថ្លៃថតចម្លង ។

ជំពូកទី ៧
អាណត្តិកាន់កាប់ដីរដ្ឋ

មាត្រា ១៨ ._

ក. រដ្ឋអាចប្រគល់ឱ្យក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីនូវសិទ្ធិប្រើប្រាស់ជាផ្លូវការ និងភារកិច្ចរក្សាការពារ ដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ ។ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលទទួលសិទ្ធិនោះ ហៅថា អាជ្ញាធរ កាន់កាប់ដីរដ្ឋ ។

ខ. អាណត្តិកាន់កាប់ដីរដ្ឋ ត្រូវប្រគល់ឱ្យតាមរយៈលិខិតគតិយុត្តជាក់លាក់ ។ អាណត្តិកាន់កាប់ដីឯកជនរបស់ រដ្ឋត្រូវប្រគល់ឱ្យតាមនីតិវិធីដែលមានចែងក្នុងជំពូកទី ៨ នៃអនុក្រឹត្យនេះ ។ អាណត្តិនេះអាចត្រូវដកហូតវិញនៅពេល ណាក៏បាន ។

គ. អាជ្ញាធរកាន់កាប់ដីរដ្ឋមានសិទ្ធិប្រើប្រាស់ដីនោះ ដើម្បីបំពេញបេសកកម្មរបស់ស្ថាប័នខ្លួន និងមានភារកិច្ចការពារដី នោះ ពីការបំពាន ឬការចូលទន្ទ្រានកាន់កាប់នានា ។

ឃ. អាជ្ញាធរកាន់កាប់ដីរដ្ឋ អាចធ្វើប្រតិភូកម្ម សិទ្ធិប្រើប្រាស់ជាផ្លូវការ និងភារកិច្ចរក្សាការពារ ឱ្យទៅមន្ទីរ ឬ ការិយាល័យខ្សែបណ្តោយរបស់ខ្លួនបាន តាមរយៈការចេញលិខិតផ្លូវការដែលបញ្ជាក់ច្បាស់ អំពីទីតាំង និងទំហំដី ជាក់លាក់ ព្រមទាំងវិសាលភាពនៃការទទួលខុសត្រូវដែលត្រូវបានធ្វើប្រតិភូកម្ម ។

ង. លើកលែងតែមានច្បាប់ចែងផ្ទុយពីនេះ ការប្តូរពីដីសាធារណៈរបស់រដ្ឋដែលបំរើផលប្រយោជន៍សាធារណៈ មួយជាក់លាក់ ទៅបំរើផលប្រយោជន៍សាធារណៈមួយផ្សេងទៀត ត្រូវកំណត់ដោយអនុក្រឹត្យ ។

ច. អាជ្ញាធរកាន់កាប់ដីរដ្ឋគ្មានសិទ្ធិជួល លក់ ផ្ទេរ ធ្វើអំណោយ ឬដោះដូរដីនោះបានឡើយ លើកលែងតែមាន កំណត់ក្នុងអនុក្រឹត្យដោយឡែក ។

ឆ. អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវទទួលខុសត្រូវ ជាមួយអាជ្ញាធរកាន់កាប់ដីរដ្ឋ ក្នុងកិច្ចការពារដីសាធារណៈ និងដីឯកជនរបស់រដ្ឋ និងត្រូវមានវិធានការទប់ស្កាត់ការបំពាន ឬការចូលទន្ទ្រានកាន់កាប់ដីរដ្ឋ ។

ជំពូកទី ៨
ការបែងចែក និងការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋ

មាត្រា ១៩ ._

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានភារកិច្ចធ្វើផែនការបែងចែកសម្រាប់ការប្រើប្រាស់ផ្សេងៗ នូវដីឯកជនរបស់រដ្ឋ ដែលបានចុះបញ្ជីរួចនៅក្នុងខេត្ត ក្រុង ហើយដែលរដ្ឋមិនទាន់បានប្រគល់ទៅឱ្យស្ថាប័ន សាធារណៈ ឬអាជ្ញាធរណាមួយកាន់កាប់នៅឡើយ ។

មាត្រា ២០ .-

ដីឯកជនរបស់រដ្ឋអាចត្រូវបានបែងចែក សម្រាប់ការប្រើប្រាស់នៅថ្នាក់ខេត្ត ក្រុង ថ្នាក់ស្រុក ខណ្ឌ ឬថ្នាក់ឃុំ សង្កាត់ ដែលត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា ២១ .-

ដីឯកជនរបស់រដ្ឋអាចត្រូវបានបែងចែកសម្រាប់ការប្រើប្រាស់ដោយបុគ្គល ឬអង្គភាពឯកជន ឬសមូហភាពតាមរយៈ

១. សម្បទានដីសង្គមកិច្ច អនុលោមតាមអនុក្រឹត្យ ស្តីពីសម្បទានដីសង្គមកិច្ច។

២. សម្បទានដីសេដ្ឋកិច្ច អនុលោមតាមអនុក្រឹត្យ ស្តីពីសម្បទានដីសេដ្ឋកិច្ច។

៣. សម្បទានផ្សេងៗទៀត អនុលោមតាមអនុក្រឹត្យដែលពាក់ព័ន្ធ ព្រមទាំងនីតិវិធី និងបទប្បញ្ញត្តិជាធរមាន។

មាត្រា ២២ .-

នីតិវិធីសម្រាប់ការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋនៅក្នុងខេត្ត ក្រុងដែលមានលក្ខណៈចូលរួម នឹង ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ។

ជំពូកទី ៤
ការខាររដ្ឋបាល និងការអនុវត្ត

មាត្រា ២៣ .-

យន្តការនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ មានដូចខាងក្រោម ÷

១- គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានទីតាំងក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និងមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង។

២- ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ មានទីតាំងក្នុងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ និងមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាស្រុក ខណ្ឌ។

មាត្រា ២៤ .-

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានសមាសភាពដូចតទៅ ÷

- អភិបាលខេត្ត ក្រុង	ជាប្រធាន
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង	ជាសមាជិកអចិន្ត្រៃយ៍
- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត ក្រុង	ជាសមាជិក
- ស្នងការនគរបាលខេត្ត ក្រុង	ជាសមាជិក
- ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្រុង	ជាសមាជិក

- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរបរិស្ថានខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរទេសចរណ៍ខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ជាសមាជិក
- នាយខណ្ឌរដ្ឋបាលព្រៃឈើ ដែលជាប់ពាក់ព័ន្ធនឹងខេត្ត ក្រុង ជាសមាជិក
- អគ្គលេខាធិការសាលាខេត្ត ក្រុង ជាសមាជិក

សមាសភាពដែលមានចែងខាងលើ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង អាចអញ្ជើញតំណាងមន្ទីរពាក់ព័ន្ធផ្សេងទៀត ចូលរួមជាសមាជិក តាមតម្រូវការនៃករណីនីមួយៗ ។

មាត្រា ២៥ ._

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានមុខងារ និងភារកិច្ចដូចតទៅ ÷

- ដឹកនាំក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌក្នុងការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អំពីអាណត្តិកាន់កាប់ និងឋានៈនៃដីរដ្ឋ
- ប្រមូល និងចងក្រងឯកសារព័ត៌មានអំពីទីតាំង ឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីរដ្ឋ
- ផ្តល់មតិយោបល់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី អំពីអាណត្តិកាន់កាប់ និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ព្រមទាំងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ
- ថែរក្សា និងធ្វើបន្តការប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋប្រចាំខេត្ត ក្រុង
- សម្រេច និងត្រួតពិនិត្យលើការរៀបចំផែនការសកម្មភាពប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ ដោយមានការចូលរួមផ្តល់មតិយោបល់លើគម្រោងសម្បទានដីធ្លី និង សហការតាមដានការអនុវត្តគម្រោងទាំងនោះ
- សហការក្នុងការរៀបចំពិគ្រោះយោបល់ជាសាធារណៈលើគម្រោងសម្បទានដីធ្លី
- លើកគម្រោងថវិកាប្រចាំឆ្នាំ និង
- បំពេញភារកិច្ចផ្សេងៗទៀត ដូចមានចែងក្នុងអនុក្រឹត្យនេះ។

មាត្រា ២៦ ._

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានលេខាធិការដ្ឋានមួយជាសេនាធិការ ដើម្បីជួយក្នុងកិច្ចការរដ្ឋបាល និងកិច្ចការបច្ចេកទេសមានជាអាទិ៍ ការបញ្ចូលទិន្នន័យ និងព័ត៌មានពីក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ការថែរក្សា និងការធ្វើចរន្តការប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ ។

លេខាធិការដ្ឋានគ្រប់គ្រងដីរដ្ឋនេះ ដឹកនាំដោយប្រធានមួយរូប ដែលជាអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ទទួលបន្ទុកការងារសុរិយោដី និងសមាជិកមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយអភិបាលខេត្ត ក្រុង ។

លេខាធិការដ្ឋាននេះ មានទីតាំងនៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ។

មាត្រា ២៧ ._

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ មានសមាសភាពដូចខាងក្រោម ÷

-អភិបាលស្រុក ខណ្ឌ ជាប្រធាន

-ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ជាសមាជិកអចិន្ត្រៃយ៍

-ប្រធានការិយាល័យជំនាញថ្នាក់ស្រុក ខណ្ឌពាក់ព័ន្ធ និងនាយផ្នែករដ្ឋបាលព្រៃឈើដែលពាក់ព័ន្ធ ជាសមាជិក

- មេឃុំ ចៅសង្កាត់ពាក់ព័ន្ធក្នុងស្រុក ខណ្ឌ ជាសមាជិក

ប្រធាន និងសមាជិកនៃក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវតែងតាំងដោយអភិបាលខេត្ត ក្រុង ។

មាត្រា ២៨ ._

ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវស្ថិតក្រោមការណែនាំផ្នែករដ្ឋបាលពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង និងក្រោមការណែនាំផ្នែកបច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ចំពោះដីរដ្ឋនៅតាមបណ្តោយព្រំដែនជាមួយប្រទេសជិតខាងទាំងបី ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវស្ថិតក្រោមការណែនាំផ្នែកបច្ចេកទេសបន្ថែម ពីគណៈកម្មាធិការបច្ចេកទេសនៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

មុខងារ និង ភារកិច្ចរបស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ មានដូចតទៅ ÷

-ប្រមូល និងចងក្រងឯកសារ ព័ត៌មានដើម្បីធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ

-សម្របសម្រួលជាមួយស្ថាប័ន អាជ្ញាធរ ឬអ្នកកាន់កាប់ដីរដ្ឋ អំពីអាណត្តិកាន់កាប់ដីរដ្ឋ

-ស្វែងរកការឯកភាពលើព្រំប្រទល់ប្រហាក់ប្រហែល ឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីរដ្ឋ

-ធ្វើការបិទផ្សាយជាសាធារណៈ នូវសំណៅព័ត៌មាន និងផែនទីដីរដ្ឋនៅតាមទីប្រជុំជន និងតាមឃុំ សង្កាត់ពាក់ព័ន្ធ និងទទួលមតិយោបល់ពីសាធារណៈ តាមកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់

-សង្ខេបមតិយោបល់សាធារណៈដែលបានទទួល និងរៀបចំទិន្នន័យ និងឯកសារចាំបាច់ រួមទាំងផែនទីដីរដ្ឋ ដែលមានបញ្ជាក់ព័ត៌មានទាំងអស់ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង

-ចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី និងផ្តល់មតិយោបល់ក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ

-រៀបចំការពិគ្រោះយោបល់ និងចូលរួមផ្តល់មតិយោបល់លើគម្រោងសម្បទានដីធ្លី ព្រមទាំងសហការតាមដានការអនុវត្តគម្រោងសម្បទានដីធ្លី និង

-បំពេញភារកិច្ចផ្សេងៗទៀត ដូចមានចែងក្នុងអនុក្រឹត្យនេះ ។

ជំពូកទី ១០

ប្រភពធនធាន

មាត្រា ២៩ .-

ថវិកាសម្រាប់ការគ្រប់គ្រងដីរដ្ឋ ដែលរួមមានការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទីដីរដ្ឋ ការធ្វើចំណាត់ថ្នាក់ ការចុះបញ្ជីដីរដ្ឋ ការថែរក្សា និងការធ្វើចរន្តការប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ ឋិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ស្របតាមប្រព័ន្ធថវិកាឯកភាព ធនធាន និងថវិកាសម្រាប់ការគ្រប់គ្រងដីរដ្ឋ បានមកពី ៖

- ថវិកាជាតិ
- ហិរញ្ញប្បទានបានមកពីក្នុង និងក្រៅប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

ជំពូកទី ១១

អវសានប្បញ្ញត្តិ

មាត្រា ៣០ .-

គោលការណ៍ណែនាំអនុវត្តអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា ៣១ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣២ .-

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

មាត្រា ៣៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការពាក់ព័ន្ធ អភិបាលគ្រប់ខេត្ត ក្រុង គ្រប់ប្រធានស្ថាប័ន អង្គភាពដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា ២៤ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-គ្រប់ក្រសួង ស្ថាប័នកណ្តាល
-គ្រប់សាលាខេត្តក្រុង
-ដូចមាត្រា ៣៣
-ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៣៤៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ សេនា ជូនប្រតិភូវៀតណាម ចំនួន ៣៩រូប ដែលគន្លងមកបានចូលរួមសហប្រតិបត្តិការយ៉ាងល្អប្រសើរ ក្នុងការអភិវឌ្ឍន៍ខេត្តជាប់ព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ដូចមានរាយនាម ខាងក្រោម :

១- លោក វុ វៀត ហាវ	VU VIET HAO	ប្រធាននាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ
២- លោក ង្វៀន ក្វាង ថាំង	NGUYEN QUANG THANG	ប្រធាននាយកដ្ឋាននយោបាយផ្ទៃក្នុង
៣- លោក ដូ ង៉ុក ស៊ើន	DO NGOC SON	ជំនួយការរដ្ឋមន្ត្រី ប្រធាននាយកដ្ឋានអាស៊ី២
៤- លោក ង្វៀន ហុង ថាវ	NGUYEN HONG THAO	ប្រធាននាយកដ្ឋានស្តីទី នៃនាយកដ្ឋានព្រំដែនភាគខាងលិច
៥- លោក ង៉ូ ធី ហ្វា	NGO THI HOA	អនុប្រធាននាយកដ្ឋានអាស៊ី២

៦- លោក ម៉ាយ ហ្វឿក យុង	MAI PHÙOC DUNG	អនុប្រធាននាយកដ្ឋានពិធីការ
៧- លោក ង្វៀន យុយ គ្វី	NGUYEN DUY QUY	អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃរដ្ឋាភិបាល
៨- លោក ផាំ ហុង ឡយ	PHAM HONG LOI	នាយរងអគ្គសេនាធិការ
៩- លោក វ៉ ទៀន ជុង	VO TIEN TRUNG	មេបញ្ជាការរងភូមិភាគ ៥
១០- លោក ជាវ ស៊ន់ ហ្វា	TRIEU XUAN HOA	មេបញ្ជាការរងភូមិភាគ ៧
១១- លោក ត្រឹន ហ្វី ហូ	TRAN PHI HO	មេបញ្ជាការរងភូមិភាគ ៩
១២- លោក លឺវ ឌឹក ហ៊ុយ	LUU DUC HUY	អគ្គនាយករង នៃអគ្គនាយកដ្ឋាន II
១៣- លោក ត្រឹន ហ្វា	TRAN HOA	មេបញ្ជាការរង កងទ័ពព្រំដែន
១៤- លោក វ៉ ថាញ់ ជីន	VO THANH CHIN	ប្រធានយោធាខេត្ត កន់ ទុម
១៥- លោក ឡេ ចៀម	LE CHIEM	ប្រធានយោធាខេត្ត ដាក់ ឡាក់
១៦- លោក រ៉ូ អូ ជៀវ	RO O CHEO	ប្រធានយោធាខេត្ត យ៉ា ឡាយ
១៧- លោក ឡេ ជុង ហៀវ	LE TRUNG HIEU	ប្រធានយោធាខេត្ត អាន យ៉ាង
១៨- លោក ត្រឹន ញៀវ	TRAN NHIEU	ប្រធានយោធាខេត្ត ដុង ថាប់
១៩- លោក ង្វៀន វ៉ាន់ គា	NGUYEN VAN KIA	ប្រធានយោធាខេត្ត ឡុង អាន
២០- លោក ង្វៀន វ៉ាន់ ត្រាំ	NGUYEN VAN TRAM	ប្រធានយោធាខេត្ត ប៊ិញ ហ្វឿក
២១- លោក ត្រឹន តុន ថឹត	TRAN TON THAT	អគ្គនាយករង នៃអគ្គនាយកដ្ឋាន សន្តិសុខ
២២- លោក ផាំង ណាំ តាវ	PHAM NAM TAO	អគ្គនាយករង នៃអគ្គនាយកដ្ឋាន តម្រួត
២៣- លោក ត្រឹន វៀត តឹន	TRAN VIET TAN	អគ្គនាយករង នៃអគ្គនាយកដ្ឋាន ចារកម្ម
២៤- លោក ប៊ុយ ក្វាង បា	BUI QUANG BA	ប្រធាននាយកដ្ឋានសេនាធិការ សន្តិសុខ
២៥- លោក ឡេ វ៉ាន់ គឿង	LE VAN CUONG	អនុប្រធាននាយកដ្ឋានសេនាធិការ សន្តិសុ.
២៦- លោក យឿង មិញ ហ៊ុង	DUONG MINH HUNG	អនុប្រធាននាយកដ្ឋានការពារ នយោបាយ I
២៧- លោក ឡេ ឌិញ ថាញ់	LE DINH THANH	អនុប្រធាននាយកដ្ឋានការពារ នយោបាយ II
២៨- លោក ង្វៀន ស៊ី ជិញ	NGUYEN SY CHINH	អនុប្រធាននាយកដ្ឋានសេនាធិការ សន្តិសុខ
២៩- លោក ដាវ កុង វិញ	DAO CONG VINH	អនុប្រធាននាយកដ្ឋានការពារ នយោបាយ I
៣០- លោក ត្រឹន ឌិញ ធូ	TRAN DINH THU	នាយកនគរបាលខេត្ត យ៉ា ឡាយ
៣១- លោក វ៉ ហ៊ុយ ហៀន	VO DUY HIEN	នាយកនគរបាលខេត្ត ឡុង អាន
៣២- លោក ប៊ុយ ង៉ក់ ហ្វុក	BUI NGOC PHUC	នាយករង នគរបាលខេត្ត ពិញ ហ្វឿក
៣៣- លោក ឡេ ហ៊ុយ ហាយ	LE DUY HAI	នាយករង នគរបាលខេត្ត កន់ ទុម
៣៤- លោក ឌិញ ង៉ុក ទឹង	DINH NGOC TUNG	នាយកនគរបាលខេត្ត ដាក់ ហ្វុង

៣៥- លោក ង្វៀន ថាញ់ ណាម NGUYEN THANH NAM នាយកនគរបាលខេត្ត កា ម៉ៅ

៣៦- លោក ឡេ វ៉ាន់ ធី LE VAN THI នាយកនគរបាលខេត្ត គៀន យ៉ាង

៣៧- លោក ង្វៀន ថាញ់ ហ្វាង NGUYEN THANH HOANG នាយកនគរបាលខេត្ត អាន យ៉ាង

៣៨- លោក ង្វៀន មិញ យុង NGUYEN MINH DUNG នាយកនគរបាលខេត្ត តាយ និញ

៣៩- លោក វ៉ រ ហ្វាយ វៀត VO HOAI VIET នាយកនគរបាលខេត្ត ដុង ថាប់ ។

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តជាប់ព្រំដែនប្រទេសកម្ពុជា-វៀតណាម ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

  (<u>ដើម្បីជូនជ្រាប</u>)
- *ដូចក្នុងមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង ស្ថាប័ន និង រដ្ឋលេខាធិការដ្ឋាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

មាត្រា ១: ត្រូវបានតែងតាំងទីប្រឹក្សា ជំនួយការ និងលេខាធិការ របស់ឯកឧត្តម ឃុន ហាំង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ក្នុងក្របខ័ណ្ឌខុទ្ទកាល័យ ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោម :

១- លោក ម៉ិច សេងហាត់ ទីប្រឹក្សា មានឋានៈស្មើ អគ្គនាយករង
២- លោកស្រី ស្មួន ត័ណា ជំនួយការ មានឋានៈស្មើ ប្រធាននាយកដ្ឋាន
៣- លោកស្រី ពេញ សេងឡូរ លេខាធិការ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា ២: បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៥
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៥៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹតលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន

សម្រេច

មាត្រា ១: ត្រូវបានបំពាក់មេដាយ **សហមេត្រី** ថ្នាក់ **សេនា** ជូនលោក និងលោកស្រី ជាជំនាញការបច្ចេកទេស UNDP ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ក្នុងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការ ដោយសារមីន ដូចមានរាយនាមខាងក្រោម :

១. លោក Dominique Pierre Guéret ជំនាញការបច្ចេកទេស UNDP ប្រចាំអាជ្ញាធរមីនកម្ពុជា

២. លោកស្រី Danielle Guéret ភរិយាលោក Dominique Pierre Guéret

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គលេខាធិការដ្ឋានអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការ ដោយសារមីន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៧៤៦..អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ឯកឧត្តមនាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីជំនួយការខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា ចំនួន ០៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិកន្លងមក ដូចមានរាយនាមខាងក្រោម :-

១-លោក **ស៊ុត រស្មី**	ជំនួយការផ្ទាល់ឯកឧត្តមនាយកខុទ្ទកាល័យ
២-លោក **កោ ចរណ្ឌី**	ជំនួយការផ្ទាល់ឯកឧត្តមនាយករងខុទ្ទកាល័យ
៣-លោក **ជា ឆៅ**	ជំនួយការផ្ទាល់ឯកឧត្តមនាយករងខុទ្ទកាល័យ
៤-លោកវរសេនីយ៍ឯក **ជុំ សោភ័ណ**	ជំនួយការផ្ទាល់ឯកឧត្តមនាយករងខុទ្ទកាល័យ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SK.60

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៥ អនក្រ.តត

អនុក្រឹត្យ
ស្ដីពី
ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរៈសេនីយ៍ត្រី **គឿន គិរម្យ** អត្តលេខ ៣៣០៨០

២- លោកអនុសេនីយ៍ឯក **ជុំ ហេខ** អត្តលេខ ៦២២១ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥

ហ៊ុន សែន

__កន្លែងទទួល :__
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៣៤៩...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនមន្ត្រីស្ថានទូត និងនាយទាហាន នាយទាហានរងពលទាហាន សហរដ្ឋអាមេរិក ចំនួន៣៦រូប ដែលមានស្នាដៃល្អក្នុងការចូលរួម ជួយសាងសង់អាគារតិលានដ្ឋាន ចំនួន ០១ខ្នង នៅភូមិព្រៃពិស ឃុំប្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោម :-

ក.មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ :

1-Ambassador Joseph Mussomeli	American Ambassador
2-Colonel Terence Tidler	Defense Attaché
3-Major Craig J. Tippins	Chief , Office of Defense Cooperation

ខ.មេដាយសហមេត្រី ថ្នាក់ សេនា :

1-LtCol Donald Baldwin	Commanding Officer, MWSS-172
2-LtCol Marshall Swor	Security Cooperation Office,MARFORPAC

3-Maj Bryan Lucas	Combat Engineer Office, MWSS-172
4-Capt Hamartriya Tharpe	Contracting Officer
5-2ndLt Jennifer Carson	Project Officer, MWSS-172

គ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ :

1-GySgt Manual Colon	Staff Non-Commissioned Officer, MWSS-172
2-Sgt Edward Hall	Platoon Sergeant, MWSS-172
3-Sgt Patrick Lapoint	Combat Engineer, MWSS-172
4-Cpl Milkel Goodman	Squad Leader, MWSS-172
5-Lcpl Gabriel Lind	Combat Engineer
6-Lcpl Kyle Mathieu	Combat Engineer
7-Lcpl Timothy Beavers	Combat Engineer
8-Lcpl Chad Currie	Combat Engineer
9-Pfc Jeffery Parks	Combat Engineer
10-Lcpl Marcus Locklear	Combat Engineer
11-Cpl Deshaun Woodson	Squad Leader, MWSS-172
12-Pfc Tyson Barnhart	Combat Engineer
13-Pfc Thomas Griswold	Combat Engineer
14-Pfc Orlando Falcon	Electrician
15-Cpl Mohamad Rascom	Electrician
16-Cpl Adam Davenport	Heavy Equipment Operator
17-Lcpl Derek Thomson	Heavy Equipment Operator
18-HMl David Maggio	Independent Duty Corpsman
19-HM3 Hector Silva	Corpsman
20-Cpl Sung Cho	Welder
21-Lcpl Charles Aldridge	Hygiene Specialist
22-Lcpl Stefan Thurnau	Drafting and Surveyor
23-Ssgt Keith Myrick	Combat Cameraman
24-Ssgt Michael Wolf	Utilities Chief
25-Lynn Nelson	AGSO, US Embassy

26-Uon Song	Purchasing Agent, US Embassy
27-Sok Hong	Procurement Clerk, US Embassy
28-Theun Sokunthea	Purchasing Agent, US Embassy

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៥៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ឈន ម៉េងឡេង** ជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អគ្គនាយករង ។

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ តុលា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ..៣៤៥.....អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែមលើអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខណ្ឌ ឋានន្តរសក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

សម្រេច

មាត្រា១: ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីចំនួន ៥រូប នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដូចមានឈ្មោះខាងក្រោម:

១-លោកស្រី **កុច ត្រឹស្នា** អោយបំពេញមុខងារជាព្រឹទ្ធបុរស នៃមហាវិទ្យាល័យបច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្ម

២-លោក **ម៉ូរ៉ា ភារ៉ា** អោយបំពេញមុខងារជាព្រឹទ្ធបុរស នៃមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ

៣-លោក **ទឹម សេដ្ឋា** អោយបំពេញមុខងារជាព្រឹទ្ធបុរស នៃមហាវិទ្យាល័យរៀបចំដែនដី និងរដ្ឋបាលដីធ្លី

៤-លោក **នួច ទិសាឈសុខ** អោយបំពេញមុខងារជានាយកសាលា ក្រោយឧត្តម

៥-លោក **ជាំ សំបូរ** អោយបំពេញមុខងារ ជានាយក ផ្នែកសិក្សា ។

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា៣
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៤៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្លាស់ប្តូរ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

ស ម្រេ ច

មាត្រា ១ : ត្រូវបានផ្លាស់ប្តូរភារកិច្ចលោក **ស៊ុន សួន** ពីប្រធាននាយកដ្ឋានអាស៊ីទី ២ មកជាប្រធាននាយកដ្ឋានអង្គការអន្តរជាតិ ។

មាត្រា ២ : ត្រូវបានប្រគល់ភារកិច្ចជូនលោកស្រី **រស់ ស៊ីម៉ារ៉ា** អោយបំពេញមុខងារ ជាប្រធាននាយកដ្ឋានអាស៊ីទី ២ ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៣២០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល ។
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងផែនការ

សម្រេច

មាត្រា១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក ទិន ទីវ អោយបំពេញមុខងារជាអធិការក្រសួងផែនការ ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៧៦១...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៏ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និង ថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

ស ម្រេ ច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដូចមានរាយនាមខាងក្រោម ៖

១_លោក **សុខ សេងយ៉ន** អោយបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល

២_លោក **ហ៊ាង ឆារ៉ា** អោយបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ ។

៣_លោក **ឆ៉ាត់ ចាន់ផល** អោយបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលសំណង់

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ... ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៧៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានចំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **CHIKAO TANAKA Head Minister of the Tenrikyo Jirin Church and Honorable President of the LOTUS Association** ជប៉ុន-កម្ពុជា ដែលមានគុណបំណាច់ និងស្នាដៃធំៗជាច្រើនក្នុងការជួយឧបត្ថម្ភដល់សិស្សានុសិស្សកម្ពុជា នៅតាមបណ្តាសាលានានា ក្នុងរាជធានីភ្នំពេញ ចំណាយអស់ថវិកាសរុបចំនួន ២៣០.០០០ ដុល្លារអាមេរិក ព្រមទាំងផ្តល់ថវិកាជាច្រើនទៀត ឧបត្ថម្ភ ដល់កាកបាទក្រហមកម្ពុជា ជួយកុមារកំព្រា មន្ទីរពេទ្យ និងជនរងគ្រោះ ដោយទឹកជំនន់ និងប្រជារាស្ត្រក្រីក្រជាច្រើនទៀត ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ តុលា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ...២០២... សហវ.ប្រក.

ប្រកាស

ស្តីពី

ការពន្យារពេលការអនុវត្តន៍អាករលើការស្នាក់នៅ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៤/០០៦ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៣៨០ សហវ.ពដ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍អាករស្នាក់នៅ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលសមាគមសណ្ឋាគារកម្ពុជា នាសម័យប្រជុំក្រុម "ឃ" នៃវេទិការាជរដ្ឋាភិបាលផ្នែកឯកជន នាថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៥ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

<u>សម្រេច</u> :

ប្រការ ១.-

ការដាក់អោយអនុវត្តប្រកាសលេខ ៣៨០ សហវ.ពដ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តន៍អាករលើការស្នាក់នៅ ត្រូវបានពន្យារពេលរហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ។

ប្រការ ២.-

បទប្បញ្ញត្តិ ឬសេចក្តីសំរេចនានាដែលមានខ្លឹមសារផ្ទុយនឹងប្រការ១នៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣.-

អគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយកដ្ឋានពន្ធដារ និងគ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥

គាត ឈន់

<u>ចម្លងជូន</u> :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- សាលាខេត្ត-ក្រុង
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧១៣៧ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេនីមល ឃីង ស្តារ មេឌីខល អ៊ីមផត & អិចផត**
ANIMAL KING STAR MEDICAL IMPORT & EXPORT Co., Ltd
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8043/05P , ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន : លោក **ឡើ សាយន្ត**
៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៩៥ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ... សេវាដឹកជញ្ជូននិងចែកចាយទំនិញ
-សាងសង់ ជួសជុល ... ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧១៣៨ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនវិនិយោគទុនឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហេង ហ៊ាប អ៊ិនវេសមេន**

HENG HEAP INVESTMENT CO.,LTD.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Inv. 978/05P ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៥

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន :

លោកស្រី	ហេង ហ៊ាប	ប្រធានក្រុមប្រឹក្សាភិបាល
លោក	ម៉ែន សារុន	អភិបាល
លោក	ជួន កុល	អភិបាល
លោក	ឡាយ ស៊ា	អភិបាល
លោកស្រី	ម៉ី ទិដ្ឋា	អភិបាល
លោកស្រី	ម៉ី សីឡា	អភិបាល
លោក	ម៉ី តារាឫទ្ធិ	អភិបាល
លោកស្រី	ម៉ី យ៉ាលីន	អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១.០០០.០០០ ដុល្លារអាមេរិក

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១២ មហាវិថីម៉ៅសេទុង សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : - រោងចក្រកែច្នៃ និងផលិតគ្រឿងសង្ហារឹមពីឈើដាំដុះ ។

៦- ថិរវេលា : ៧០ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-ក្រសួងបរិស្ថាន- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាគុំព្យូទ័រ
- សាលាក្រុងភ្នំពេញ-មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- សាលាខេត្តកំពង់ចាម - មន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៦១៤៧ ពណ.នគក/

ភ្នំពេញថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ស្ពែនខេម អ៊ិនធើណេសិនណល ខនស្ត្រាក់សិន វើក អិលធីឌី**

SPAINCAM INTERNATIONAL CONSTRUCTION WORKS Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 2564/05E** ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន

លោក	**ម៉ុខ ពន្លក**	ប្រធានក្រុមប្រឹក្សាភិបាល
លោក	**IGNACIO ARIAS SUAREZ**	អភិបាល
លោក	**JOSE SANCHEZ ALARCON**	អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១២០.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២ A ផ្លូវលេខ ២២៨ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ - សិក្សាគំរោងប្លង់និងគូរប្លង់គ្រប់ប្រភេទ
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ
នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបកប្រែ[illegible]
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម: រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។៚

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧១៤៦ ពណ.ឧតក/

ភ្នំពេញថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ផាន់ លក្ខិណា ខូ អិលធីឌី**

PHAN LEAKHENA Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8042/05P ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥

មានទម្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : កញ្ញា **ផាន់ លក្ខិណា**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : អគារសង់ថ្មី ភូមិបាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

៥- កម្មវត្ថុអាជីវកម្ម : -អាជីវកម្ម សេវាកម្ម លើចំណតយានយន្ត

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ

-ការជួល ការជួសជុល បញ្ញើ ការដាក់ឃ្លាំងនូវផលិតផលគ្រប់បែបយ៉ាង ទំនិញ សំភារៈ វត្ថុគ្រប់ប្រភេទមកពីគ្រប់ប្រភព នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-បើកគ្លីនិកព្យាបាលជំងឺ

-ទិញ លក់ ជួល បញ្ចាំ ចលនៈ និងអចលនទ្រព្យ

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន

-វិនិយោគនិងអភិវឌ្ឍន៍លើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគនិងអភិវឌ្ឍន៍លើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តបន្ទាយមានជ័យ
- មន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៦១៤៩ ពណ.នគក

ភ្នំពេញថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេមប្រាយ**

CAMBRIGHT Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8033/05P ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៥

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន
លោក HOTTA KAZUHITO ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **លឹស ចំនួតិនដារ** អភិបាល
លោក **សម សារី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១១៥ ផ្លូវលេខ ២១៤ កែង ៦៣ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្មៈ រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
[ហត្ថលេខា និងត្រា]
ចិម ស៊ីថន

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧១៥៦ ពណ.នតក

ភ្នំពេញថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ណាក្រា ឌីវេឡុបមេន**
NAKRA DEVELOPMENT Co., Ltd
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2570/05E ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៥
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន : លោក **LINMACHAVADEE VIBOONE**
៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៥៧៤ ផ្លូវជាតិលេខ១ សង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដូសជុលសំភារៈទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

